# English for Study in Australia
# កម្មវិធីភាសាអង់គ្លេសសម្រាប់ការសិក្សានៅប្រទេសអូស្ត្រាលី

LESSON 14 – An Aussie Barbecue

**មេរៀនទី១៤ ៖ ការជួបជុំគ្នាអាំងសាច់ទទួលទានកំសាន្តតាមបែបអូស្ត្រាលី**

## STUDY NOTES
ឯកសារជំនួយមេរៀន

<u>Characters</u>

<u>តួអង្គ</u>

Angel:

អែនជល ៖ និស្សិតអន្តរជាតិ។

Katie:

ខេតធី ៖ និស្សិតអន្តរជាតិ។

Rocky:

រ៉ុកឃី ៖ និស្សិតអន្តរជាតិ។

John:

ចន ៖ និស្សិតបរទេសនៅសាកលវិទ្យាល័យ។

Magda:

ម៉េកដា ៖ មិត្តស្រីរួមផ្ទះរបស់អែនជល។

Kel:

ឃែល ៖ មិត្តប្រុសរួមផ្ទះរបស់អែនជល។

<u>សាច់រឿង</u>

មិត្តទាំងអស់បានមកចូលរួមពិធីអាំងសាច់មួយដែលរៀបចំឡើងដោយអែនជល និងម៉េកដា។

**<u>ព័ត៌មាន - ពិធីអាំងសាច់តាមបែបអូស្ត្រាលី</u>**

នៅប្រទេសអូស្ត្រាលី ការអាំងសាច់គឺជាពីធីដ៏ពេញនិយមមួយសម្រាប់ការជួបជុំគ្នា។ នៅចុងសប្តាហ៍ ប្រសិនបើអាកាសធាតុអំណោយផល ហើយគ្មានការហាមឃាត់មិនឲ្យដុតភ្លើងនោះ ផ្សែងនិងក្លិននៃការអាំងសាច់ក្រក និងសាច់បន្ទះប្រភេទផ្សេងៗប្រាកដជានឹងរសាត់អណ្តែតនៅតាមផ្លូវជាយក្រុងនានាជាក់ជាមិនខានឡើយ។ ប្រសិនបើមានការអញ្ជើញលោកអ្នកឱ្យចូលរួមក្នុងកម្មវិធីអាំងសាច់ ជាធម្មតា លោកអ្នកត្រូវយកអាហារផ្ទាល់ខ្លួន ដើម្បី


© RadioAustralia/AMES 2008
ABC Radio Australia

ធ្វើការចម្អិនរួមគ្នា ព្រមទាំងយកភេសជ្ជៈទៅជាមួយផង។ នៅក្នុងកម្មវិធីអាំងសាច់ ជាធម្មតា មានការលេង "កីឡាគ្រីកែត" ឬបាល់ទាត់។ លោកអ្នកគួរចូលរួមលេងកីឡាណាមួយ ដែលភ្ញៀវដទៃទៀតកំពុងលេង។ ការលេងកីឡារួមគ្នានេះ គឺជាវិធីដ៏ប្រសើបំផុតក្នុងការចងក្រងមិត្តភាព។ សូមមើលវិបសាយថ៍ដែលមានភ្ជាប់មកជាមួយនៅខាងចុងឯកសារជំនួយមេរៀននេះ អំពីវិធានក្នុងការលេងកីឡាមួយចំនួនដែលគេនិយមអនុវត្តនៅក្នុងប្រទេសអូស្ត្រាលី។

**<u>ភាសា-សំនួនវោហារ និងឃ្លាប្រយោគដែលមានន័យមិនធម្មតា</u>**

| | |
|---|---|
| "Hey!" | ជួនកាលត្រូវគេប្រើជំនួសពាក្យថា "hi ឬសួស្តី" ដើម្បីសម្តែងការស្វាគមន៍។ |
| BYO | Bring your own មានន័យថា "សូមយកមកជាមួយនូវភេសជ្ជៈឬសុរាផ្ទាល់ខ្លួន"។ ប៉ុន្តែ ក្នុងសំបុត្រអញ្ជើញ ពេលខ្លះលោកអ្នកអាចមានឃើញសរសេរថា "BYO pinic" មានន័យថា "ការកម្សាន្តក្រៅគេហដ្ឋាន ដោយការយកអាហារផ្ទាល់ខ្លួនទៅបរិភោគ" ឬ "BYO meat" មានន័យថា "ការអាំងសាច់ដោយយកសាច់មករៀងៗខ្លួន"។ |
| "I'm glad you could make it." | ខ្ញុំត្រេកអរណាស់ដែលអ្នកអាចឆ្លៀតមកបាន។ |
| uni | សាកលវិទ្យាល័យ |
| "How do you like Melbourne?" | តើអ្នកយល់ឃើញយ៉ាងម៉េចដែរចំពោះទីក្រុងមែលប៊ិន? |
| "Anyone for a snag?" | តើមាននរណាត្រូវការសាច់ក្រកទេ? |
| "Help yourself" | សូមយកដោយខ្លួនឯងចុះ។ |
| (to) take a joke | ទទួលយកការកំប្លែងលេងសើច ដោយពុំមានការអាក់អន់ចិត្តដោយការលេងសើចនោះទេ។ |


© RadioAustralia/AMES 2008

| | |
|---|---|
| (to) give someone a hand | ជួយនរណាម្នាក់។ |
| Finger food, hors d'oeuvres | ជាអាហារមានទំហំតូចល្មមដាក់ក្នុងមាត់បានដែលពេញនិយមនៅក្នុងពិធីជប់លៀង សម្រាប់ឱ្យអ្នកចូលរួមបរិភោគក្នុងពេលឈរនិយាយគ្នា ដោយមិនចាំបាច់ប្រើកាំបិត ឬសមឡើយ។ |

## EXERCISES
## លំហាត់

### ១. វាក្យសព្ទសំខាន់ៗ

សូមផែកអត្ថន័យ និងការបញ្ចេញសំឡេងនៃពាក្យទាំងអស់នេះនៅក្នុងវចនានុក្រមរបស់លោកអ្នក ៖

| | | |
|---|---|---|
| beach | beer | breeze |
| Cricket (game) | drinks | funny |
| guest | hilarious | host/hostess |
| joke | (to) marinate | misunderstanding |
| plastic | rude | sausage |

### ២. ការហាត់រៀនភាសា លំហាត់គំរូ-តេស្តស្ទង់កម្រិតសមត្ថភាពភាសាអង់គ្លេស

ដើម្បីឲ្យគេអាចរៀបចំដាក់លោកអ្នកទៅក្នុងវគ្គសិក្សាណាមួយ លោកអ្នកត្រូវឆ្លងកាត់ការធ្វើតេស្តដើម្បីស្ទង់កម្រិតសមត្ថភាពភាសាអង់គ្លេសជាមុនសិន។ សូមកត់ចំណាំថា ការណែនាំក្នុងការធ្វើតេស្ត ជាទូទៅ សរសេរជាភាសាអង់គ្លេស (ដូចខាងក្រោម)។

សូមជ្រើសរើសពាក្យដែលសមស្របបំផុត សម្រាប់ដាក់បំពេញឃ្លានីមួយៗនៅខាងក្រោម


© RadioAustralia/AMES 2008

**Milestone birthdays**

In Australia, we don't celebrate name days.  We celebrate birthdays; that is, the anniversary of the day we ______1______ born.  Two of the main birthdays that young people celebrate are eighteenth birthdays and twenty-first birthdays.  This is ______2______ eighteen is the age when a teenager can legally vote, drive and drink alcohol.  The legal voting age was lowered ______3______twenty-one to eighteen in the 1970s but people still invite friends and family to their "twenty-first" to celebrate ______4______coming of age. From then on the big birthdays celebrated are the ones ending in zero.  Thirty, forty, fifty, sixty and so on, are all ______5______milestone birthdays.

ABC Radio Australia

សូមគូសខ្វែងនៅក្នុងប្រអប់មួយ សម្រាប់លេខនីមួយៗ។ ឧទាហរណ៍: ☒

| | | | | |
|---|---|---|---|---|
| 1. | ☐ was | ☐ is | ☐ were | ☐ be |
| 2 | ☐ for | ☐ why | ☐ since | ☐ because |
| 3. | ☐ from | ☐ for | ☐ since | ☐ though |
| 4 | ☐ there | ☐ they're | ☐ their | ☐ these |
| 5 | ☐ considered | ☐ consider | ☐ thought | ☐ liked |

៣. ឧបសគ្គក្នុងការប្រើប្រាស់ភាសា

សូរសំឡេង / æ / ៖ សូមហាត់និយាយពាក្យដែលតម្រូវឲ្យមានការខំប្រឹងពត់អណ្តាតរួចបញ្ចេញសំឡេងឲ្យបានឮៗ ៖

"The fat cat sat on the mat."


© RadioAustralia/AMES 2008

## ៩. អាសយដ្ឋានអ៊ីនធើណែតមានប្រយោជន៍

| | |
|---|---|
| ព័ត៌មាន ៖ វិន័យក្នុងការលេងបាល់ទាត់របស់ប្រទេសអូស្ត្រាលី | http://www.upfromaustralia.com/ausrulfoot.html |
| របៀបលេងកីឡាគ្រីកកែត | http://www.latifm.com/look/Sports_Cricket.htm?userid=Givesmart&userip=203.34.40.2&useragent=Mozilla%2f4.0+(compatible%3b+MSIE+6.0%3b+Windows+NT+5.1%3b+InfoPath.1) |
| របៀបលេងបាល់ទះ | http://www.sportsunlimitedinc.com/volleyballrule.html |

ចម្លើយលំហាត់ទី 2: 1) were 2) because 3) from 4) their 5) considered

ABC Radio Australia
radioaustralia.net.au
AMES
www.ames.net.au
© RadioAustralia/AMES 2008